# ២

# ទំព័រជីវិតថ្មី

ម៉ោង ៩ព្រឹកហើយ .....

លោកពិសិដ្ឋវង្សដើរចុះដើរឡើង មើលចូលមកខាងក្នុងបន្ទប់បន្តិចរួចក៏ស្រដីថា ÷

- ប៉ាមិនជំទាស់នឹងអាពាហ៍ពិពាហ៍របស់កូនទេ.... ប៉ុន្តែប៉ាមានសំណូមពរមួយចំពោះកូន !

- មានប្រសាសន៍មកចុះប៉ា សំណូមពរយ៉ាងម៉េចខ្លះ ?

- ប៉ាមានតែកូនមួយ ជាត្រួយជីវិតរបស់ប៉ា រឿងរបស់កូននិងមុនីឃើញថាស្និតស្នាញនឹងគ្នាណាស់ អ្វីៗទាំងអស់កើតមកពីល្បិចថៅកែហ្វាងឡុងទេ ប៉ាក៏លែងគិតទៅទៀតដែរ ប៉ុន្តែប៉ាមិនចូលចិត្តនារីលេងកុនសោះ ! ហេតុនេះបើមានកូនប្រសាជានារីលេងកុនទៅហើយ ប៉ាសុំអោយកូនអនុគ្រោះដល់ប៉ានូវចំណុចពីរខាងក្រោមនេះ ÷

- បើកូនការរួចមានកូនប្រុស ប៉ាទុកកូននោះឱ្យកូនចិញ្ចឹមរក្សាទីពីរបើមានកូនស្រី ប៉ាសុំយកកូនស្រីរបស់ឯងមកចិញ្ចឹម ហើយសុំផ្តាច់ចេញពីឯងដាច់ខាតថា វាជាកូនប៉ាបង្កើតដើម្បីកុំឱ្យវាមានទំនោរ ងាកទៅរកសិល្បៈលេងកុនដូចម៉ែវាទៀត !



ពិសិដ្ឋនរៈភ្ញាក់នឹងសំដីនេះពេកកន្លង ÷

- ប៉ា ! អោយតែខ្ញុំមានកូនស្រី ប៉ាសុំយកទាំងអស់ឬ ?

- អាចថាយ៉ាងហ្នឹងក៏បាន ! ប៉ុន្តែប៉ាកំលាំងចាស់ប្រហែលរស់នៅមិនយូរ ដើម្បីចិញ្ចឹមកូនស្រីរបស់ឯងអោយបានគ្រប់ចំនួននោះទេ ប៉ាត្រូវខិតខំធ្វើយ៉ាងណាកុំអោយចៅស្រីរបស់ប៉ាក្លាយទៅជាតារាភាពយន្ត

- ប៉ា ! បើដូច្នេះប៉ាមិនយល់ព្រមទទួលស្គាល់អូនមុនីថាជាកូនប្រសាទេឬ ?

- ប៉ាមិនប្រកាន់ដល់ម្លឹងទេ ប៉ុន្តែជ្រុលតែមួយបានហើយ កុំឱ្យតពូជពង្សតទៅទៀត ! កូនស្រីប៉ាចង់អោយចេះខាងវិជ្ជាមេផ្ទះ ឬជាកវីនិពន្ធ ដែលមានលក្ខណៈរស់នៅស្ងប់ស្ងាត់ មិនកញ្រ្ជោកបោកបែននោះទើបសមតាមបំណងប៉ា ! បើកូននៅនឹកអាសូរប៉ា គួរកូនធ្វើតាមពាក្យខាងលើនេះផង !

ពិសិដ្ឋខាំមាត់ហើយសំរេចចិត្ត ។

- ប៉ាដើម្បីសុខភាពរបស់ប៉ា និងដើម្បីអោយអាពាហ៍ពិពាហ៍របស់កូនប្រព្រឹត្តទៅដោយសុខសាន្ត កូនយល់ព្រមតាមពាក្យសុំរបស់ប៉ាហើយ !

លោកពិសិដ្ឋវង្សទះស្មាកូនតិចៗ ÷

- ល្អណាស់ ! នរៈប៉ានឹងរង់ចាំទទួលចិញ្ចឹមកូនស្រីរបស់ឯងកំដរវ័យចាស់ជរារបស់ប៉ានៅគ្រាចុងបំផុតនៃរបស់គោលបំណងរបស់ប៉ា !

នរៈសំលឹងមុខប៉ាគេទាំងក្តីវិយោគ ÷

- កូនសូមអោយរៀបការរួច បានកូនស្រីមួយសំរាប់យកមកជូនប៉ាដើម្បីអោយប៉ាបានសំរេចតាមបំណង ! កូនស្តាយណាស់ ដោយរូបកូនមិនបានជាទីពេញចិត្តនៃប៉ា រីឯកូនប្រសាប៉ាក៏ខុសបំណងប៉ាទៀត !

លោកពិសិដ្ឋវង្សបញ្ចេញដង្ហើមយូរ ÷

- អ្វី១ជាព្រេងវាសនាបានចារមក..... ប៉ាត្រូវតែខំរក្សាសុខភាពឱ្យល្អ ក្រែងថ្ងៃការបណ្តាលអោយឈឺ ទៅជាខកខានមិនបានចូលរោង នាំអោយអំពល់វែងឆ្ងាយ រឿងនេះប៉ាសំរេចថាយល់ព្រមតាមឯងហើយ ចុះខាងស្រី ?

- បាទប៉ា ! ខាងស្រីក៏មិនជំទាស់អ្វីទៀតដែរ !

- ចុះមហាជន ?

- មហាជនកំពុងតាមដានរឿងនេះខ្លាំងណាស់ដែរ !

- មុនីមានសុខភាពល្អមាំមួនឡើងវិញហើយឬ ?

- បាទប៉ា ! នាងមាំមួនហើយ តែសាច់នៅស្លាំងបន្តិច !

- តើឯងនៅតែអនុញ្ញាតិអោយប្រពន្ធឯងលេងកុនតែរហូតឬ ?

នរៈទ្រឹងបន្តិចដែរ ÷

- រឿងនេះមិនកំណត់ទេប៉ា ! កាលណាចាស់បន្តិចទៅ យើងនាំគ្នាប្រែការងារថ្មីទៀតក៏មិនដឹង !

- អូហ៍ ! កុំរៀននិយាយយ៉ាងនេះកូន តួកុនចាស់ណាស់មានការពិសោធន៍ច្រើន ងាយនរណាអោយឈប់លេង គេនឹងដើរតួជាឪពុកឬម្តាយទៅទៀតមិនខាន ! ហ៊ឺ .... មើលទៅប្រពន្ធឯង លេងកុនមួយ



អាយុហើយ ហើយកុំភ្លេចបណ្តាំប៉ាអោយសោះណាំ ! តែប្រពន្ធឯងឆ្លងទន្លេ បានកូនស្រីយកមកអោយប៉ាភ្លាម !

នរៈយល់ព្រមតែខ្លួនឯង គេពុំដឹងថាតើមុនីយល់ព្រមតាមគេឬមិនព្រមទេ ប៉ុន្តែឃើញឪពុកជូរចត់ខុសបំណងរបស់គាត់ច្រើនដងពេក មាណពមិនដាច់ចិត្តអោយគាត់អស់សង្ឃឹមជាថ្មីទៀតសោះ អ្នកក៏យល់ព្រមគ្មានគិតគូរយូរ ។

ម៉ោង ៦ ល្ងាច នរៈត្រឡប់មកពីគេហដ្ឋានឪពុករបស់គេ វិលទៅកាន់ផ្ទះភានុមារិញ ក៏បានជួបមុនីអង្គុយចាំគេជាស្រេច ។ នាងក្រមុំបានជានា ដុះសក់ប្រហែលមួយធ្នាប់ដៃ មុខស្រស់ផ្លូវផង់តែនៅស្លាំងនៅឡើយ ។ យល់សង្សារមកដល់ភ្លាម មុនីស្ទុះទៅទទួល ÷

- បងនរៈ !

- មុនីអូន ! រឿងយើងបានសំរេចហើយ ប៉ាបងលែងប្រឆាំងទៀតហើយ ប៉ុន្តែគាត់មានសំណូមពរមួយយ៉ាងចំលែក !

- ចំលែកយ៉ាងម៉េចទៅបង ?

នរៈរៀបរាប់គោលបំណងរបស់ឪពុកគេប្រាប់មុនី ហើយជួយសំរួលថា ÷

- អូនថតកុន បងជាអ្នកភ្លេង យើងរវល់ណាស់ ! បើប៉ាគាត់ធានាចិញ្ចឹមកូនយើង ដូច្នេះស្រួលយើងហើយ ធម្មតាកូនវាមិនភ្លេចម៉ែភ្លេចឪទេ !

មុនីងក់ក្បាលតិច១ ÷

- បើគាត់គ្រាន់តែធានាចិញ្ចឹម អូនមិនសូវគិតប៉ុន្មានទេ ! ប៉ុន្តែក្រែងគាត់បង្គាប់វា មិនអោយស្គាល់យើងដូចម៉ែឪធម្មតាណាបង !

- គាត់ត្រូវការតែកូនស្រីទេ បើយើងមានកូនប្រុស គ្មានបញ្ហាអ្វីទាំងអស់អូន កូនយើងមិនមែនសុទ្ធតែស្រីនោះទេ យ៉ាងហោចណាស់ក៏មានប្រុសមួយនឹងគេដែរ !

អ្នកទាំងពីរនិយាយគ្នាដល់នេះ ស្រាប់តែក្រហមមុខរៀងខ្លួន ព្រោះគេមិនទាន់ចូលរោងការផង ស្រាប់តែជជែកគ្នារឿងកូនទុកជាមុនទៅហើយ ។

ភានុមាដើរចូលមកដោយចំអន់ថា ÷

- យី ! ប្រុងបើកកាតាឡុកមើលមុខកូនអោយល្អ ដូចតួឯកប្រទេសណាហ្នឹង ? បានជាជជែកគ្នាឮៗម្ល៉េះ ?

មុនីរិតតែអៀន នរៈនិយាយសើចៗ ÷

- ភានុមា ! រឿងគ្នានិងមុនីនៅតែថ្ងៃចូលរោងការទេ ចុះឯងថ្ងៃណាចូលរោងការនឹងគេ ? យ៉ាងម៉េចៗ កុំដណ្ដឹងកូនគ្នាទុករឿយ !

ទាំងអស់គ្នាសើចក្អាកក្អាយ .......

មួយខែក្រោយមក អាពាហ៍ពិពាហ៍រវាងតារាឯកភាពយន្តមុនីនិងយុវជនអ្នកភ្លេងពិសិដ្ឋនរៈ បានប្រារព្ធឡើងយ៉ាងគគ្រឹកគគ្រេង ល្បីពាសពេញទីក្រុង ដោយមានភ្ញៀវជាច្រើន ចូលរួមយ៉ាងច្រើនកុះករ ។ សំលេងពរជ័យសិរីមង្គលជាច្រើនបានលាន់ឡើង ជូនពរដល់គូស្វាមីទាំងពីរ អោយបានរួមរស់នឹងគ្នាប្រកបដោយសុភមង្គលគ្រប់ប្រការ ។



ឥឡូវនេះស្នេហារបស់គេទាំងពីរបានសំរេចហើយ ដោយមានអាពាហ៍ពិពាហ៍ជាអះអាង ។ តើរសជាតិស្នេហារបស់សង្សារគ្រប់រូបមានន័យបរិបូរណ៍ទៅលើភ្លេងការតែប៉ុណ្ណោះទេឬ ? ប្រហែលមិនទាន់បរិបូរណ៍នៅឡើយទេ ព្រោះពេលនេះមុនីបានរស់នៅក្បែរនរៈជានិច្ចការមែនហើយ តែនាងនៅភ័យៗ នឹងកូននាងដែលកើតមកជាស្រី ត្រូវប្រគល់អោយលោកពិសិដ្ឋវង្សទាំងអស់ ។ មុនីសុំបន់ស្រន់អោយកូននាងកើតមកដំបូងជាកូនប្រុសទៅ ។

ការហើយបួនខែ មុនីមានទំងន់បីខែហើយ ÷

- ឱ ! អស់លោកទេវតារក្សាទ្វីបលោកទាំងប្រាំអើយ មេត្តាអោយខ្ញុំកើតបានកូនប្រុសមុនមក ដើម្បីអោយបានជាកូនខ្ញុំពិតៗ !

នរៈអាចយល់ចិត្តភរិយាបានយ៉ាងច្បាស់ គេខំលួងលោមនាងថា ÷

- មុនីអូន ! ប៉ាចិញ្ចឹមក៏ដូចម៉ែឪចិញ្ចឹមដែរ អូនដូចជាបារម្ភពេកហើយ !

- បងនរៈ ! អូនស្រលាញ់កូនណាស់ តែបងបានជាជ្រុលសន្យាទៅហើយ ទើបអូនមិនអាចប្រកែកកើត បើកូនយើងស្រីអូនចំបែងណាស់ រស់បែកពីកូនតើអូនអាចទ្រាំបានដែរ ?

- ចាំហេតុការណ៍កើតមានសិន ចាំព្រួយអូន ! បើអូនព្រួយមុនហេតុការណ៍ គឺថតកុនលែងកើតហើយ ប៉ាបងមានបំណងចិញ្ចឹមបំប៉នវាឱ្យក្លាយទៅជានារីរៀនសូត្រ តែបងជឿថា បើម្នាក់ប្រហែលជា

គាត់ចង់បាន ប្រសិនបើបីបួននាក់ គាត់នឹងធុញទ្រាន់រុញអោយយើងខ្លះវិញមិនខានទេ !

- តើបងជឿថាអូនអាចបង្កើតបុត្របានរាប់ផ្លូនឬ ?

- មិនបាច់ផ្លូនទេ ត្រឹមតែ ៦ នាក់អីបានហើយ ប្រុស៣ ស្រី៣ សមល្មមនឹងសមត្ថភាពយើងចិញ្ចឹមបាន ។ ប្រុស៣ ឱ្យវាធ្វើមេធាវីម្នាក់សំរាប់ជួយម៉ែវាពេលមានរឿង ម្នាក់ទៀតឱ្យធ្វើអធិការចាប់ចង ស្រួលការពារសន្តិសុខអោយម៉ែវា ហើយចុងក្រោយឱ្យធ្វើពេទ្យដើម្បីពិនិត្យម៉ែវាពេលឈឺ .... និងកូនស្រីបីនាក់ទៀត តាឱ្យធ្វើអីស្រេចតែគាត់ចុះ !

- បងគិតតែអូន ! ចុះរូបបង តើបងគិតអោយកូនយើងវាជួយខាងអ្វីខ្លះ ?

- ចំពោះបងមិនសំខាន់ទេ ! អោយតែអូនបានរីករាយ យកកូនទៅបំរើអោយអស់ចុះ !

មុនីសើចភ្លេចទុក្ខព្រួយមួយគ្រា ។

ធ្មេចបើក១ ពេលវេលាបានរំលងទៅយ៉ាងឆាប់រហ័ស មុនីបានឆ្លងទន្លេរួចហើយ កូននាងកើតមកស្រីមុនគេបង្អស់ ដូច្នេះលោកពិសិដ្ឋវង្ស ដែលឈរចាំស្តាប់លទ្ធផល បានសំរេចសុំយកទៅចិញ្ចឹមភ្លាម គ្មាននិយាយស្តីអ្វីច្រើនឡើយ ។ មុនីខំកាត់ចិត្តហុចកូនស្រីទៅអោយឪពុកក្មេក ដោយមិនហ៊ានសំរក់ទឹកភ្នែកឡើយ ។

លោកពិសិដ្ឋវង្សទទួលចៅមកបី និយាយលួងលោមកូនប្រសាថា ÷



- កូនស្រី ! ចូរកូនកុំព្រួយបារម្ភអោយសោះ ប៉ាធ្លាប់ចិញ្ចឹមរក្សានរះរហូតដល់រស់បានជាមនុស្ស ដូច្នេះប៉ាក៏មានសមត្ថភាពបរិបូរណ៍អាចចិញ្ចឹមរក្សាចៅស្រីអោយមានសុខភាពល្អបរិបូរណ៍បានដែរ កូនស្រីមានប្តីនៅថ្នាក់ថ្នមថៃ ... ឆ្នាំនេះកូនសំរាលបានកូនស្រីមួយ ឆ្នាំក្រោយកូនអាចសំរាលបានកូនប្រុសមួយទៀតជំនួសវាមិនខាន... ទេវតាអាណិតប៉ាទើបប្រទានកូនស្រីមកមុន ដើម្បីឱ្យប៉ាបានចិញ្ចឹមវា ចូរកូនអាណិតប៉ាដែលរស់នៅតែម្នាក់ឯង មានចៅស្រីបន្លែងដូច្នេះ លែងកើតទុក្ខទៀតហើយ .... កូនទាំងពីរខំរក្សាគ្នាណា ! ឆ្នាំក្រោយសុំឱ្យឯងបានកូនប្រុសមួយទៀតដូចបំណង !

មុនីសំលឹងកូនភ្លៀក១ ប៉ុន្តែសំដីឪពុកក្មេក នាងគួរអាណិតដែរ នាងដណ្តើមកូនប្រុសគាត់មកធ្វើជាប្តី ឥឡូវគាត់ដណ្តើមកូននាង យកទៅចិញ្ចឹមវិញរួចគ្នាហើយ ។

- ប៉ា ! បើកូនទៅលេងអោយកូនជួបមុខវាផង !

- មិនអីទេ ប៉ានឹងអោយវាចេញមកទទួល ប៉ាលាសិនហើយណា៎ ! នរះកូនប្រឹងប្រែងការពារប្រពន្ធអោយមែនទែន សរសៃខ្ចីកុំឱ្យយំច្រើនប្រយ័ត្នទាស់ !

មុនីខំលេបទឹកភ្នែកចូលទៅវិញ ÷

- កូនមិនយំទេប៉ា ! រឿងនេះយើងបានដឹងមុនរួចទៅហើយ !

លោកវង្សមិនហ៊ាននៅយូរទេ ខ្លាចក្រែងមុនីកែប្រែចិត្តទារយកកូនវិញ ព្រោះគាត់គ្រាន់តែជាអ្នកបីបាច់ មិនមែនជាឪពុកទារិកានេះ

ឡើយ គាត់ឃើញមុនីគោរពសំដីមិនកិកកុក គាត់អរណាស់ និយាយខ្សឹប១តែក្នុងចិត្តថា "ចៅស្រីអញនឹងក្លាយទៅជានារីម្នាក់ សុភាពរាបសា គេឯងលាន់មាត់សរសើររាប់អាន មានប្ដីជាមនុស្សត្រឹមត្រូវ មិនមែនជាអ្នកលេងកុនដូចម៉ែវាទៀតឡើយ !" ។

គ្មានសូញសាញ ខ្លាចទារកនោមដាក់ឬជុះដាក់អ្វីទេ លោកវង្សបីចៅមកឱ្យស្ត្រីចំណាស់ម្នាក់ គាត់នេះអរណាស់ ម្ដីម្នាទទួលពីដៃគាត់ ។

- ស្រីហើយ មែនទេលោក ?

- ស្រីមែន ! តោះយើង !

មីងចែមស្ត្រីមេដោះដែលលោកវង្សជួលទុកមុន ម្ដីម្នារូតរះរៀបចំចេញដំណើរតតបង្អង់ ។

លោកវង្សញញឹមស្រស់ថ្លា ហើយចរចានឹងមីងចែមថា ÷

- អ្នកចែម ! ប៉ុន្មានឆ្នាំមុនអ្នកចិញ្ចឹមនរៈ ឥឡូវនេះអ្នកត្រូវចិញ្ចឹមកូនស្រីវាបន្តទៀត ! ខ្ញុំសុំឱ្យអ្នកប្ដូរបច្ចេកទេសចិញ្ចឹម កុំឱ្យវាចិត្តធំដូចនរៈទៀត ត្រូវអោយវាមានចិត្តទោរទន់មករកអ្នកមានគុណខ្លះផង ចៅស្រីខ្ញុំនេះបើវាធំឡើងបែកគំនិតលេងកុនទៀត ខ្ញុំនឹងសំលាប់ខ្លួនមុនមច្ចុរាជមកឆក់យក ហើយអ្នកចែមអាណិតខ្ញុំ មុននឹងបំបៅវាត្រូវឧបកិច្ចថាអោយមានចិត្តទន់ភ្លន់ណា !

- ចាស ! លោកប្រុស ខ្ញុំនឹងប្ដូរវិធីថែរក្សាវាហើយ ដើម្បីឱ្យវាមានចិត្តកាត់រកលោកប្រុស ! សូមលោកប្រុស ឧស្សាហ៍ឈរមើលមុខវា អោយវាឃើញខ្សែភ្នែកលោកប្រុស វានឹងយល់តាមលោកប្រុសជា



មិនខាន !

- សូមអោយទេវតាមេត្តាខ្ញុំ បញ្ចៀសចៅស្រីខ្ញុំអោយវាផុតពីដើរតួកុនមួយមុខចេញ ខ្ញុំអរណាស់លោកអើយ ...!

ដោយសារតែមូលហេតុចង់ឱ្យចៅស្រីរបស់គាត់ស្អប់កុន លោកវង្សបានប្រគល់គ្រឹះស្ថានរកស៊ីទាំងអស់ អោយនរៈកាន់កាប់ជំនួសហើយរូបគាត់បានលាឈប់នៅភ្នំពេញទៅរស់នៅជនបទវិញ ។

ផ្ទះលោកវង្សនៅឯជនបទ សង់របៀបបុរាណនិយម មានទីធ្លាស្រឡះល្អណាស់ លោកវង្សប្រិតព្រៀងចិញ្ចឹមរក្សាចៅស្រី ហាមឃាត់គេឯងកុំអោយនិយាយប្រាប់វាថាមានម្ដាយជាអ្នកលេងកុន ។ គាត់ហៅចៅស្រីថាកូន១ហើយភរថានាងជាកូនគាត់បង្កើត ។ គោលបំណងលោកវង្សអោយតែចៅស្រីគាត់មានអាយុគ្រប់ ១០ ឆ្នាំ គាត់នឹងបញ្ជូនទៅឱ្យរៀនវិជ្ជាមេផ្ទះនៅឯប្រទេសជប៉ុនមិនខាន ។ គាត់បញ្ជូនចៅស្រីអោយទៅរៀនពីតូចដូច្នេះ ដើម្បីការពារកុំអោយម៉ែវាស្គាល់ផង និងការពារកុំអោយចៅស្រីគាត់ មានគំនិតចង់លេងកុនដូចម៉ែវាទៀត ។ លោកវង្សបានដាក់ឈ្មោះចៅស្រីគាត់ថា ពិសិដ្ឋវង្ស ដានី ។

..........................................................

ប្រាំឆ្នាំបានកន្លងទៅហើយ កេរ្តិ៍ឈ្មោះតារាឯកភាពយន្តមុនី នៅតែល្បីល្បាញសុះសាយដដែល ប៉ុន្តែគួរអោយអាណិតនាងណាស់ ៥ ឆ្នាំនេះនាងមានតែបុត្រីមួយគត់ ហើយកូននោះត្រូវឪពុកក្មេកនាងយកទៅចិញ្ចឹមទៀត ។ មុនីនឹកកូនរាល់ថ្ងៃ កាលណានាងសំដែងកុនគំសត់ព្រាត់

កូន មុនីយំមែនទែន បណ្តែតអារម្មណ៍ទៅរកកូនស្រីដែលជីតាយកទៅលាក់បាត់ ។

នរៈតែងសង្ឃឹមថា គេនឹងបានកូនប្រុសម្នាក់ទៀត នៅថ្ងៃណាមួយមិនខាន ប៉ុន្តែប្រាំឆ្នាំនេះ គេទាំងពីររង់ចាំមើលផ្លូវកូនដែលមកចាប់ផ្ទៃឡើងផ្សាភ្អែក ។

គ្មានអាទិទេពណាមកចាប់ផ្ទៃនឹងមុនីទៀតសោះ តើនាងត្រូវទំនេរពោះរហូតឬ ? គ្រូពេទ្យពិនិត្យសុខភាពនាងបានជំរាបនាងថា ÷

- នាងមិនទាន់អស់កូនទេ !

ដោយសារពាក្យមួយឃ្លានេះ ទើបមុនីមានសង្ឃឹមក្នុងការរស់នៅបន្តិច ។

សូមងាកមកមើលលោកវង្សបន្តិច ដើម្បីអនាគតចៅស្រី លោកវង្សសុខចិត្តលះបង់ភាពទីក្រុង មករស់នៅឯជនបទ ។ ក្បែរលោកគឺកុមារីតូចមួយអាយុ ៥ ឆ្នាំ ចងសក់កំប៉ោយពីរ កំពុងតែអង្គុយលេងល្បែងផ្សេងៗ ។ លោកវង្សទិញចានឆ្នាំងផង និងប្រដាប់ប្រដាដណ្តាំឱ្យវាលេង ។ កុមារីដានីឈ្ងូសចោលខ្ទេច ÷

- អត់លេងទេប៉ា !

- កូនលេងទៅសប្បាយណាស់ !

- អត់សប្បាយទេ !

ជាមួយនឹងពាក្យអត់សប្បាយ នាងតូចចង្អុលទៅគោ ÷

- ជិះគោប៉ា !



លោកវង្សមិនចូលចិត្តសោះ គាត់នឹកគិតតែក្នុងចិត្ត "ជិះគោបើក្មេងប្រុសវាសម ព្រោះបង្រៀនឱ្យវាក្លាហានមិនខ្លាចគ្រោះថ្នាក់ ចំណែកក្មេងស្រីជិះគោអីដែរ រៀនសូទៅវាត្រូវជាង"

- ជិះគោខ្លាចគ្រោះថ្នាក់កូន ! គោរត់លឿនចាប់មិនទាន់ ដួលបាក់ដៃជើងចេញឈាមឈឺណាស់ !

កុមារីដានី ស្រាប់តែទារខ្លាំងៗថា ÷

- ជិះកប៉ា ! ជិះកប៉ា !

លោកវង្សខ្លាចកូនយំ ក៏ហុចកអោយចៅជិះ ÷

- ហ៊ឺ ! អញ្ជើញជិះមកកូនស្រី ! អនាគតកូនស្រីឯងបែបជិះកប្តីឯងហើយ !

កុមារីមិនយល់ថាប្តីជាអ្វីទេ នាងតូចគិតតែសប្បាយនឹងបានជិះកប៉ាវា ។

- ប៉ាសប្បាយណាស់ !

លោកវង្សបញ្ជិះចៅលើករហូតដល់មាត់ទ្វារ បែកញើសជោគនៅក្នុងបន្ទប់របស់ចៅស្រីគាត់ លោកវង្សទិញកូនក្រមុំស្អាតៗ គ្រប់ធុនយកមកទុកអោយចៅស្រីលេង ។ កុមារីពុំសូវពេលេង ឬប្រលែងលេងដូចគេទេ នាងតូចចូលចិត្តលេងសក់កូនក្រមុំ ហើយយកកន្ត្រៃមកកាត់សក់កូនក្រមុំកញ្ជៃកញ្ជតអស់រលីង ពេលខ្លះទៀតនាងតូចច្រលំដៃយកកន្ត្រៃមកកាត់សក់លោកតាដាច់អស់ជាច្រើនផងដែរ ។ លោកវង្សនៅតែសើចជានិច្ច ទោះបីសក់កញ្ជតមួយដុំ ឬខ្ចីមួយកំណាត់ក្បាល ក៏គាត់

មិនខឹងដែរ កុំអោយតែចៅស្រីរបស់គាត់ក្លាយជាអ្នកលេងកុន ។

អាយុបានប្រាំមួយឆ្នាំ ជីតារបស់ដានី បានយកនាងអោយទៅរៀនអក្សរខ្មែរនៅសាលាជនបទ ។ ដានីរៀនឆ្លាតណាស់ ហើយឬកពាប្លែកពីកុមារដទៃទាំងអស់ លេងស្អីក៏ដោយ ដានីតាំងខ្លួនជាមេកើយគេទាំងអស់ក្នុងចំណោមមិត្តភក្តិតូចៗរបស់ដានី មានកុមារីខ្លះអាយុ ៧-៨ ឆ្នាំ ដានីនៅតែថាគេអន់ជាងជានិច្ច ។

ថ្ងៃអាទិត្យនេះ កុមារាកុមារីក្នុងភូមិទំនេរខ្លួនពីសាលា នាំគ្នារត់លេងឈូឆរក្នុងភូមិ គេពិនិត្យឃើញក្នុងចំណោមនោះ មាននាងតូចដានីមួយដែរ ។

នាងតូចស្លៀកខោប៉ោងជើងតូចខ្លីពណ៌ខៀវត្រឹមភ្លៅ ចងសក់ទីទុយ ពាក់អាវហោប៉ៅធំៗពីរ កាន់ថ្មគ្រួសតូចៗបួនប្រាំដុំ សំរាប់លេងត្រិះ ។ កុមារាខ្លះនាំគ្នាកាន់កាំភ្លើងលេងបាញ់ទឹកដាក់គ្នា ..... កុមារីខ្លះនាំគ្នាព័ទ្ធវង់ត្រិះគ្រួសលេង ខ្លះទៀតឈូសទឹកសើចកក្អឹក ។

ដានីដាក់កូនកន្ត្រៃមួយជាប់នឹងហោប៉ៅជានិច្ច ទៅដល់ពីមុខក្រុមលេងត្រិះ នាងតូចសុំគេប៉ាវហើយដាក់ខ្លួនចុះសុំលេងដែរ ។

- អោយគ្នាលេងផង !

- ចូលមក !

- គ្នាតអោយលេងមុន !

កុមារីបីនាក់ទៀតសើច ÷

- អានី ថាវាពូកែ តក៏ត ......



- តអោយហើយ បើចាញ់គ្នាទៀត គ្នាសុំសក់ហើយ !

- អើ ! យកសក់យកទៅចុះ ! បើវាចាញ់យើង ?

- បើអញចាញ់ អញទិញនំ ១០៛ អោយស៊ី !

- អើ ! ខំលេងវ៉ើយ បាន ១០៛ ទិញនំស៊ី !

កុមារីបីនាក់ព្រួតគ្នាលេងតទល់ជាមួយនាងតូចដានី ដែលអង្គុយធ្វើឬកយ៉ាងខែង ត្រិះថ្មលេងឈ្នះពួកដៃគូយ៉ាងងាយ ។

- ឈ្នះហើយ នៅអោយស្ងៀមណាំ !

- កាត់សក់អញ ! ម៉ែអញថាអត់អោយលេងក្បាលទេ ខ្លាចអាប់ប្រាជ្ញារៀនមិនចេះ !

- ម៉ែអញមិនឱ្យគេកាន់ក្បាល គាត់ថាអញចេះតែឈឺក្បាល !

- កុំកាន់ក្បាលអញវ៉ើយដានី !

កុមារីដានីដើរក្រវែលមិត្តវាពីរបីនាក់ ដែលប្រកែកញ៉ាញមិនព្រមអោយកាត់សក់ រើសយកហេតុផលផ្សេងៗមកប្រកែក ។ វាធ្វើមុខក្រញ៉ូវច្រត់ចង្កេះបើកភ្នែកធំៗ មើលទៅមិត្តតូចៗរបស់វា ÷

- ចុះពេលអញសុំសក់ ម៉េចមិនប្រាប់អញ ?

- អញភ្លេច !

- អើ អោយអញកាន់ក្បាលកាត់សក់បន្តិចទៅ បើម៉ែវាសួរថាភ្លេចទៅណាំ ! មិនអោយអញកាន់ក្បាលក៏បានដែរ អោយអញកាត់សក់អត់កាន់ក្បាលទេ ! តែមិនអោយអញកាត់សក់ អញទៅហៅពួកប្រុសៗមកដេញឆាឆៅនៅពេលវាទៅសាលា !

- អញ្ចឹងកាត់ទៅ ! តែកាត់សក់អញត្រង់ណាខ្លីៗ បានហើយណាំ !

- អើ ! អញកាត់ខ្លីទេ !

កាលបើគេព្រមឱ្យកាត់ហើយ ដានីលូកហោប៉ៅយកកូនកន្ត្រៃដើរកាត់សក់គេគ្រប់ចំនួន ។ នាងតូចច្រឹបបន្ទិចស្រែកថា ÷

- នៅអោយស្មើម វែងម្ខាងហើយ !

- ចៀរអោយស្មើ ខ្លាចម៉ែអញស្ទួរ !

- កាត់កុំងាកបានល្អ ហ៊ុ ... មិនអោយអញកាន់ក្បាលខ្លីខ្លះវែងខ្លះ អញមិនដឹងទេ !

- កាន់ៗទៅ ! ចាំអញភូតម៉ែអញថាភ្លេច !

ដានីលើកដៃភ្លែត ចាប់ក្បាលគេច្បូតសក់លេងយ៉ាងរំភើយ ។

- ដានី ! ទាញសក់អញឈឺណាស់ !

ដានីសើចតែក្នុងចិត្តម្នាក់វា ÷

"ភ្លើៗអោយអញលេងក្បាល អញទាញសក់វាទៅហើយមិនអោយឈឺ ?"

ដានីស្ទាបទាញសក់គេគ្រប់គ្នា ហើយក៏ឈប់លេង ដាក់កន្ត្រៃចូលក្នុងហោប៉ៅអាវដើរទៅក្រុមឈូសមីក ។ វាឈរមើលគេឈូសមីកឬកខែងណាស់ ដៃពីរលូកហោប៉ៅអាវស្ទាបកន្ត្រៃលេង ហើយសុំចូលលេងជំនួសនាងតូច ដែលឈូសដួលរបកជើងសុំឈប់ ។ វាឈ្នះឈ្នះគេទៀតហើយ គេអោយវាបូលយកផ្ទះ ដានីបូលត្រង់ផ្ទះកណ្តាលវាគ្រវីក្បាលថា ÷



- អញអត់យកទេ ទាល់តែបូលបានផ្ទះលើបានអញយក !

វាក្រាញនៀលទាល់តែបូលបានផ្ទះមេក្លោងដំបូល ទើបព្រមយក ។ កុមារីទាំងអស់បានសំរាក ហើយគិតនាំគ្នាលេងស្តេចចង់ ស្រីនៅម្ខាងប្រុសនៅម្ខាង ឯដានីវាលើកដៃភ្លែតសុំធ្វើស្តេច ដើម្បីអោយគេទៅគាល់វាប្រាប់ថាស្រលាញ់នរណាៗ ....

វាអង្គុយចំកណ្តាលសើចស្ញេញ រលាស់សក់កំប៉ោយពីរមើលទៅលើសើចវាហឺ ដោយពុំមានចោលភ្នែកទៅរកនរណាអោយដឹងខ្លួនអ្វីឡើយ ។

ចាស់ៗលាន់មាត់ថា ដានីនៅតូចសោះ តែឫកពាវាដូចមនុស្សចាស់ ។ ពួចាស់ៗពោលសរសើរបែបនេះ ដានីខំតែងតាំងខ្លួនធ្វើឫកជាមនុស្សធំលើសដើម ។ ធម្មតាក្មេងកាលណាពួគេខ្សិបថាស្រលាញ់ឈ្មោះនេះ ឈ្មោះនោះតែងតែសើចហើយចោលភ្នែកដៀងរកសាម៉ីខ្លួន តែស្តេចដានីមិនដូចក្មេងដទៃទេ វាអង្គុយយ៉ាងហ្នឹងមើលទៅលើ ហើយគ្មានបង្ហាញឫកពារលីមរលាម ឬចោលដើមភ្នែកកន្ទុយភ្នែកមើលអីទេពួកប្រុសៗនាំគ្នាល ។

- ហក ! អាចក់ទៅសាកលមើល ?

ដានីគ្មានញ្ញោចទេ នាងតូចគួសដីធ្វើមិនដឹង ។

- ដានីអត់ភ្ញាក់ទេវ៉ើយ ! បែបគ្មានឈ្មោះអាចក់ទេ ទៅភ្លាមអាចក់ !

អាចក់ធ្វើជាឈានជើងប្រុងរត់ ហើយដកមកវិញ ក្រែងដានីភ្ញាក់ស្រែកហៅថាគេ តែស្តេចដានីនៅនឹង មិនមានភ្ញាក់អ្វី១ទាំងអស់ កាច់ដៃប្រស១យ៉ាងរំភើយ .... ចក់ទុកចិត្តទាំងស្រុងថាគ្មាននរណាខ្សិបឈ្មោះគេទេ ក៏រត់រឹងទៅរកដានី ។

ដានីក្រោកឈរលើកដៃឡើងប្រកាស ÷

- បងណែនខ្សិបប្រាប់ថាស្រលាញ់បងចក់ !

ចក់ទន់ជង្គង់ចង់ដួល ខំសាកល្បងដានីដែរ នៅតែស្មានមិនដឹង

- ប្រុស១ចាញ់ហើយ ស្រី១សុំអោយអ្នកចាញ់ឡើងដើមស្លាបេះអោយគេយកទៅជូនចាស់១ក្នុងភូមិពិសាម្លូរ !

កុមារាពេលនេះដែលលេងធំជាងគេ អាយុ ១២-១៣ឆ្នាំ និងតូចជាងគេអាយុ ៩ ឆ្នាំ ប្រតោងដើមស្លារបូត១ ពុំមានកុមារណាម្នាក់ឡើងរួចឡើយ ព្រោះភ្លៀងពីយប់មិញ រអិលព្រិលដូចគេលាបប្រេង ។

- ឡើងមិនរួចទេ ! អោយធ្វើស្អីផ្សេងទៅ !

ដានីឈរមើលហើយសើច បង្វិលខ្លួនប្រុងត្រឡប់ទៅផ្ទះ ប៉ុន្តែក្រុមឈ្នះនិងក្រុមចាញ់មិនព្រមឈប់តវ៉ាគ្នាសោះ ។

- ចាញ់គេត្រូវបេះស្លា !

- ឡើងហើយតើ ដូច្នេះរួចគ្នាហើយ !

- ឡើងមែន តែមិនដល់លើ មិនត្រឹមត្រូវទេ !

- ចង់ត្រឹមត្រូវ ឡើងខ្លួនឯងទៅ !

- ប្រុស១កំសាកធ្វើចាញ់គេហើយលេបសំដី !



- ស្រី១បានតែប្រើ បើរអិលអាណាឡើងរួច ? ប្រើដូចជាគ្មានភ្នែក ស្មានថាងាប់គេខ្លួនរកកូនប្រុសឯណាសងម៉ែគេបានឬ ? តិចពិបាកយំស្ងា !

ដានីថយមកក្រោយវិញ ហើយញញឹម ÷

- កុំអោយអ្នកចាញ់រួចខ្លួន ខ្ញុំអ្នកបញ្ជាវិញ !

កុមារីទទួលយល់ព្រមតាម ÷

- អើ ! អោយដានីបញ្ជាចុះ !

ដានីដកកន្ត្រៃពីហោប៉ៅ រួចប្រកាស ÷

- ខ្ញុំសុំកាត់សក់ម្នាក់បន្តិច១ ទុកជាអនុស្សាវរីយ៍ !

ក្មេងប្រុស១ទាំងអស់លាន់មាត់ ស្រែក យី ! ព្រមគ្នា ។

- ងាប់ហើយ ! សក់ខ្លីផង កាត់ខ្លីថែមទៀត មានសក់ឯណាសិត ?

- ស្លាប់ហើយ កន្ត្រៃដានីប៉ុនមេដៃ កាត់សក់គ្នារឆិញរឆុញ ទៅណាមកណាចូលចំណោមគេមិនចុះទេ !

- ស្អែកបុណ្យឡើងសាលា ដានីអើយ ! ជាងកាត់សក់ដូចដានីឯង ខ្លាចតែគេមិនអោយចូលវត្តទេ ស្មានតែសក់អាវ៉ង !

ខាងកុមារីចង់ធ្វើបាបកុមារា ក៏ទាមទារអោយកុមារាទាំងនេះធ្វើតាមពាក្យដានី ។ កុមារាខឹងណាស់តែមិនហ៊ានប្រកែក ព្រោះកុមារីបានប្រើធមិព្រមានធូន់១ថា ÷

- អ្នកណាចាញ់គេហើយគេចខ្លួន សូមអោយអ្នកតាក្រហមក

កាច់កើតឃ្លង់ទៅលោក !

កុមារាទាំងនោះខ្លាចពាក្យនេះណាស់ ព្រោះអ្នកស្រុកជនបទតែងមានជំនឿខ្លះៗ ហើយឆ្លងមកដល់ក្មេងៗទៀតផង ។

កាលបើកុមារាព្រមហើយ ដានីក៏ដើរកាត់សក់គេគ្រប់គ្នា ។ តើដានីចូលចិត្តកាត់សក់មែនឬ ? មើលចុះនាងតូចច្បូតសក់គេចុះឡើងទាញទៅមុខទៅក្រោយទាល់តែម្ចាស់គេធុញ ធ្វើមុខជូរហ្មួញ ទើបលែងមកវិញ ។ ដោយសារដានីចូលចិត្តលេងសក់គេយ៉ាងនេះហើយ ទើបនាងតូចមានលក្ខណៈពិសេសម្យ៉ាង ស្គាល់សក់មនុស្សធំ និងមនុស្សតូចច្បាស់លាស់ ។ សក់សរសៃឆ្មារ សក់សរសៃតូច សរសៃក្រាស់ សក់ចាស់មានពណ៌យ៉ាងម៉េចៗ ដានីកាត់ចំណាំតែខ្លួនឯងបានយ៉ាងងាយ ។ ក្រោយពីកាន់សក់គេលេង នាងលួចកាត់សក់យកទៅទុកមើលបានក្រាស់ក្រែលហើយដានីក៏វិលត្រឡប់ទៅផ្ទះវិញដោយសប្បាយ ។

ក្បែរគល់ស្វាយមួយដើមត្រង់ផ្លូវដែលដានីដើរទៅកាន់ផ្ទះ គេឃើញកុមារាម្នាក់ កាន់កូនស្នាតូចមួយនៅក្នុងដៃ កំពុងឈរស្ងៀមតាមសំលឹងមើលសត្វដើម្បីបាញ់ ។

ដានីឈប់ង៉ក់គិតថា ÷

"អាអ្នកកាន់ស្នានេះដូចជាមិនដែលឃើញ ? វាមកពីណាមក ? ស្នាវាកាន់ដូចជាគួរអោយចង់លេង តើអញធ្វើម៉េចនឹងដណ្តើមបាន ?"

កុមារាកាន់ស្នាមានអាយុ១១ ឆ្នាំហើយបងដានី ៥ ឆ្នាំប្រហែលតែដានីគ្មានគោរពគេជាធំទេ គិតរើស្មើតែម្តង ។



ដានីដើរទៅជិតកុមារកាន់ស្នាហើយញញឹមបន្តិច ដើម្បីទាក់ចិត្តក្មេងនោះអោយទន់ចិត្តមកលើវា ។ កុមារាកាន់ស្នាបែរមុខចេញ ព្រោះវាមិនស្គាល់ដានីសោះ ។

- មីតូច ! ស្បៀកខោប៉ោងនេះសើចដាក់នរណា ?

ដានីខឹងណាស់ខំសើចដាក់គេ គេមិនទទួលយកសំណើចរបស់វាវាឈប់សើចហើយឈរសំលក់កុមារកាន់ស្នា ។ កុមារាកាន់ស្នាប្រុងបាញ់សត្វទៅហើយ ស្រាប់តែឮសូរអ្នកណាហៅវា ÷

- ពណ្ណរាយ ! អើ ពណ្ណរាយ !

វាឮដូច្នេះក៏លែងបាញ់ ហើយរត់ទៅក្រោមដើមស្វាយ កាយដឹកប់ស្នាយ៉ាងលឿន ទើបរត់ទៅរកអ្នកហៅ ÷

- លោកតា ! ខ្ញុំនៅឯណេះ !

ដានីស្គាល់ច្បាស់ណាស់ លោកតាដែលហៅពណ្ណរាយ គឺជាអ្នកជិតខាងរបស់នាង គាត់ឈ្មោះតាសំ ប្រពន្ធគាត់ឈ្មោះយាយសូត្រ ជាគ្រួសារខ្សត់មនុស្សណាស់ ។

ចុះពណ្ណរាយនោះមកពីណា ? ដូចជាមិនដែលឃើញ ?

ដានីសើចដាក់តាសំ ÷

- តា ! អត់អញ្ជើញទៅវត្តទេ ?

- អូហ៍ ! ដានីទេ ! តាមកពីវត្តវិញហើយចៅ ! ចុះឯងមកពីណាទៅណា ?

- ខ្ញុំមកពីលេងមីក !

តាសំអង្អែលក្បាលដានី ÷

- ឮថាឯងពូកែរកស្លូវ និងចូលចិត្តកាត់សក់គេ ចៅឯងធំ ឡើងចង់ធ្វើជាជាងកាត់សក់ឬ ?

ដានីសួរមកវិញ ÷

- ធ្វើជាងកាត់សក់ដូចពូចាន់នោះឬតា ? មិនល្អសោះ ដើរយួរកន្ត្រៃឡើងផ្ទះគេ !

តាសំសើច ÷

- ម៉េចក៏មិនល្អ ? នរណាក៏ត្រូវការកាត់ដែរ មួយខែបើចាន់មិនកាត់សក់អោយទេ ម្នាក់ៗភ័យណាស់ ព្រោះសក់វែងខ្មាសគេ ចៅឯងដឹងទេ មនុស្សមានមុខមាត់ល្អយ៉ាងណាក៏ដោយ អោយតែសក់វែងស្រមេមស្រមាមលែងល្អហើយ សក់សំខាន់ណាស់ណាំ !

ដានីឆ្លើយតបមកវិញថា ÷

- ប៉ាខ្ញុំថាស្រីត្រូវរៀនខាងវិជ្ជាមេផ្ទះ ឱ្យចេះដាំស្លពូកែទើបល្អ ! តា ! ធ្វើមេផ្ទះសំរាប់តែគេប្រើម៉េចក៏ល្អ ? ខ្ញុំចង់ធ្វើអ្វីដែលប្រើគេហើយពូកែជាងគេ !

និយាយដល់នេះស្រាប់តែលេចលោកវង្សជីតាដានីដើរមកដល់÷

- ដានី ! ថ្ងៃនេះកូនឯងដើរបាត់យូរម្លេះ ?

ដានីរត់ទៅតោងកជីតា ÷

- វរល់តែសប្បាយណាប៉ា !

តាសំគាត់ដឹកដៃចៅប្រុសគាត់ម្ខាង ហើយដៃម្ខាងទៀតទះស្មា



លោកវង្ស ÷

- វង្ស ! ឮថាឯងចង់អោយកូនស្រីទៅរៀនវិជ្ជាមេផ្ទះឬ ? នៅឯប្រទេសជប៉ុនមែនទេ ? តើទៅអង្កាល់ ?

លោកវង្សលើកចៅស្រីពរ ហើយឆ្លើយដោយញញឹមថា ÷

- ទាល់តែអាយុ ១០ ឆ្នាំ ទើបបញ្ជូនទៅ ! ចុះសំឯងបានចៅប្រុសមកពីណាដឹកដៃ ?

- នេះជាចៅខ្ញុំបង្កើតណាំ ! ឪពុកវាជាចៅកែកូនធំណាស់នៅភ្នំពេញ ខ្ញុំមិនចូលចិត្តសោះ ! មុខរបរដូចឪពុកវា ព្រោះវរល់ជាប់រហូតមិនសូវបាននៅថែទាំម៉ែឪទេ ! ខ្ញុំចង់អោយចៅខ្ញុំ រៀនអោយបានជ្រៅជ្រះ ធំឡើងអោយធ្វើពេទ្យដើម្បីរក្សាខ្ញុំ ដូច្នេះហើយទើបខ្ញុំសុំវាពីកូនស្រីខ្ញុំយកមកចិញ្ចឹម !

- ធំប៉ុននេះហើយ ទើបសុំវាមក វាស្គាល់ម៉ែឪវា វាព្រមធ្វើតាមសំឯងដែរ ?

- ប្រពន្ធខ្ញុំធ្វើមេដោះចិញ្ចឹមវាតាំងពីតូចមក ដូចវង្សឯងឃើញស្រាប់ហើយ ប្រពន្ធខ្ញុំមិនដែលនៅភូមិទេ ព្រោះនៅថែរក្សាវានេះណាំ ! ឥឡូវខ្ញុំចាស់ហើយ ទើបកូនស្រីខ្ញុំគេអាណិតដាច់ចិត្តអោយកូនមកខ្ញុំថែ ខ្ញុំអោយវាចូលរៀនហើយ ! ពណ្ណរាយជំរាបសួរតាវង្សទៅកូន !

ពណ្ណរាយជំរាបសួរតាវង្សតាមបញ្ជាតាវា ÷

- ជំរាបសួរលោកតា !

- អើៗ ! ល្អហើយចៅ !

ដានីបែរមុខចេញ ហើយនឹកខឹងនឹងពណ្ណរាយ ចង់តែរករឿង ព្រោះអម្បាញមិញ វាខំសើចដាក់ពណ្ណរាយបែរងាកមុខចេញ ។

តាវង្សគាត់ប្រាប់តាសំថា ÷

- បើចង់អោយចៅសំឯងធ្វើពេទ្យ ត្រូវឧស្សាហ៍បណ្ដុះគំនិតវា អោយវាលេងសំភារៈពេទ្យ អោយវាឧស្សាហ៍ទៅពេទ្យ ហើយនាំពេទ្យណាមួយអោយវាស្គាល់ដើម្បីអោយធ្វើតាម !

តាសំឆ្លើយដោយញញឹម ÷

- ខ្ញុំកំពុងតែធ្វើដូចវង្សឯងថានេះហើយ ក្មេងប្រុសដទៃទៀតចូលចិត្តលេងបាញ់កាំភ្លើងគ្នា ទាល់តែឈាមដៃឈាមជើង ខ្ញុំតែងតែហាមចៅខ្ញុំ មិនអោយប្រព្រឹត្តល្បែងទាំងនេះទេ ព្រោះវានាំអោយចិត្តពាលកាចសាហាវ ខ្ញុំរកសំភារៈពេទ្យអោយវាលេង !

ដានីងាកមុខមកវិញយ៉ាងលឿនមើលទៅពណ្ណរាយ ហើយគិតថា ÷

"មិញអញឃើញវាលេងកាំភ្លើង ប្រហែលវាលួចលេងហើយទើបឃើញតាវាមកប្រញាប់យកទៅលាក់ បើអញចង់ឱ្យវាត្រូវរំពាត់ ប្រាប់តាវាតែបន្តិច វាច្បាស់ជាយំមិនខាន ! ហ៊ឹស ! តែអញជាក្មេងចាស់ចិត្តចាស់គំនិតដូចមនុស្សធំ អញមិនខ្វីរវល់នឹងរឿងវាទេ !

ឃើញដានីងាកមើលវា ពណ្ណរាយចេះតែលួចសំលឹងមើលវិញទាំងមុខមិនធម្មតា ។ កុមារនោះចេះតែភ័យៗ ... មីតូចនេះហោប៉ៅវាដេរធំៗណាស់ វាមិនមែនជាក្មេងស្លូតទេ ព្រោះគ្រាន់តែហោប៉ៅវាដេរ



ប៉ុណ្ណឹង ក៏អាចអោយដឹងថា វាជាក្មេងប្រមូលល្បែងលេងច្រើនណាស់ ទាល់តែហោប៉ៅទូញ មុខវាសើចពូកែលាក់រឿងនានា ហើយសក់វាចងយ៉ាងស្រួល គឺជាក្មេងម្នាក់ពូកែសំដីផងហើយឆ្លាតណាស់ វាមិនស្គាល់អញសោះ ! តិចវាប្រាប់តាអញ ថាអញលេងកាំភ្លើងជាមិនខាន ព្រោះវាចង់អោយអញត្រូវរំពាត់ដើម្បីបានសប្បាយចិត្ត មុខវាហ្នឹងប្រហែលជាចង់សើចនឹងឃើញគេយំណាស់ អោយតែហ៊ានប្រាប់តាអញ ថ្ងៃណាមួយដែលស្ងាត់ល្អ អញលួចវ៉ៃវាអោយកប់ភក់បឹងឈូកម្ដង !

គិតយ៉ាងនេះហើយ ពណ្ណរាយក៏សំលក់ត្មែមករកដានីវិញ ធ្វើអោយនាងតូចក្ដៅក្រហាយជាខ្លាំង ។

- ចុះវារមាស់ភ្នែកម្ល៉េះ ? ចេះតែសំលក់អញ ! នែ៎ បើកុំតែអញត្រូវគេចាត់ទុកជាក្មេងចេះមានគំនិតចាស់ទុំ កុំអីអញចាក់រុកតាវាអោយវ៉ៃវាហើយ ឬវាដឹងថាអញជាក្មេងចិត្តចាស់ទុំ ហើយចង់លអញឱ្យខឹងដើម្បីនិយាយដើមអញ ? អញមិនខ្វីចាញ់បោកវាទេ ! អញកាន់តែក្បាលក្មេងៗធំជាច្រើន អញជាក្មេងថ្នាក់អន្ទ្រើស អញមិនទៅជ្រលក់មាត់និយាយរឿងតូចតាចតចឹងទេ វាប្រហែលមិនដឹងថាអញពូកែលើសគេ ក្បាលគេគ្រប់ៗគ្នាប្រកាន់ ហើយគោរពណាស់ តែចំពោះអញៗ កាន់ក្បាលពួកណាក៏បានដែរ ហើយថ្ងៃណាមួយអញនឹងកាន់ក្បាលវាអោយដូចជាក្បាលគេគ្រប់គ្នាជាមិនខាន !

ក្មេងទាំងពីរមានគំនិតផ្ទុយស្រលះ ។ ពណ្ណរាយភ័យនឹងកំហុសខ្លួនរអើលៗ ខ្នង រីឯដានីខ្លួនប៉ុនកដៃតែឫកប្រហែលវីរៈនារី ចាត់ទុក

រឿងផ្សេងៗសុទ្ធតែធុនទាប ហើយអ្វីដែលវាធ្វើសុទ្ធតែធុនខ្ពស់ ។

ចាស់ៗទាំងពីរជជែកគ្នាជាហូរហែ រីឯក្មេងទាំងពីរអោយតែខ្សែភ្នែករត់ប៉ះគ្នា ផ្កាភ្លើងអស្មិមានះបញ្ចេញមកប្រឆាំងគ្នា ដោយស្វ័យប្រវត្តិ ។

ទៅដល់ផ្ទះដានីញ៉ាំបាយរួចរត់ចូលបន្ទប់ភ្លាម ហើយទាញសក់ដែលវាលួចកាត់បាន យកមកដាក់ក្នុងប្រអប់មួយយ៉ាងធំ ហើយសើចញញឹមនិយាយតែម្នាក់ឯងថា ÷

- ក្បាលអាមួយនោះ មូលទ្រវែងដូចផ្លែភ្នៅ ខំតំរង់ទៅតាមក្បាលវា សក់វាទៅជាស្ដើងខំប្រឹងកាត់នោះប្រឹង ។ ក្បាលអាមួយទៀតសក់រឹងកំព្រឹស គោតណាស់ បែបវាអត់មុជទឹកទេដឹង ? បានជាសក់វាបះជ្រោងពត់លែងចុះក្រោម ខឹងពេកចាប់ដកសក់វាចោលអស់សន្ទឹកវាស្រែករំពង ! យី ! កាន់ក្បាលគេសប្បាយមែន ធ្វើអ្វីក៏បានដែរ ព្រោះភ្នែកមើលមិនឃើញ ។

កុមារីដៃខូចនេះ បើកភ្នែកភ្លឹះៗ មើលទៅរូបកូនក្រមុំ ហើយគិតតទៅទៀតថា ÷

"ថ្ងៃមុនឃើញពូចាន់កាន់ក្បាលពូម៉នមេស្រុក ។ ពូម៉នឮគេថាកាចណាស់ គាត់ស្រែកអោយគេរាល់គ្នាចង់រាគអាចម៍ តែទីបំផុតគាត់អោនក្បាលអោយពូចាន់កាត់សក់គ្មានក្អកមួយម៉ាត់ ។ យី ! ខ្ញុំគិតធ្វើជាងកាត់សក់ហើយធំជាងគេទាំងអស់ !"

សំរេចចិត្តដូច្នេះរួចហើយ ដានីសប្បាយចិត្តណាស់ វាបិទភ្នែក



គេងទាំងញញឹមពព្រាយ ។ ព្រឹកឡើងដានីស្លៀកពាក់ស្អាតបាតដើរទៅរៀនតែឯង ជាទំលាប់របស់វា វាតែងចូលហៅមិត្តវាម្នាក់ទៀត អោយដើរទៅជាមួយវា ។ តែព្រឹកនេះវាចង់ដើរទៅរកដើមស្វាយ ដើម្បីលួចមើលកន្លែងកប់កាំភ្លើង ទើបមិនបានហៅមិត្តអោយរួមដំណើរ ។

វាចេះតែអួតខ្លួនវាថា ÷

"អញទៅលួចមើលកាំភ្លើងគេដូច្នេះ ដូចមនុស្សធំឬដូចកូនក្មេង គេសរសើរអញថា ដូចមនុស្សធំគ្រប់ៗគ្នា តិចអញមកលួចចាំមើលកាំភ្លើងគេយ៉ាងនេះគេថាអញធ្វើឫកដូចកូនក្មេងទៅ ? អន់ណាស់រឿយ !"

តែគំនិតក្មេងវានៅតែក្មេង ចង់បានគេសរសើរនោះហួសពីចង់ហើយ តែចិត្តចង់លេងសើចនោះ ក៏សែនមហាចង់ណាស់ដែរ ។ ដានីដើរលបៗរួចហើយលុតជង្គង់ចុះ រាវរកកន្លែងក៏ប៉ះដីទន់ៗវាកាយភ្លាម ...... កាំភ្លើងក៏បង្ហាញរូបរាងឡើង ដានីម្ទីម្ទាស្រវាលើកយកមកមើល កំពុងតែផ្ទៀងផ្ទងមើល ស្រាប់ឮសូរជើងទីបៗរត់មកដល់ ដានីគេចមិនទាន់រកច្រកក្រវាត់កំភ្លើងចោលទៅកន្លែងដើមវិញ វាឮសូរមាត់ក្មេងប្រុសម្នាក់និយាយឡើងថា ÷

- យី ! មានចោរលួចរបស់គេកប់ចោលហ្ន៎ ! ចោរនេះមានសក់វែង ហើយចងត្រឹមត្រូវល្អណាស់ ជាចោរថ្នាក់ធំ !

ដានីមិនដឹងទេ វានឹកក្នុងចិត្តថា ÷

"អញជាមនុស្សចាស់ចិត្តចាស់គំនិត វាជាក្មេងវាមិនដឹងថា អញជាមនុស្សពូកែជាងគេទេ គង់ថ្ងៃណាមួយហុចក្បាលឱ្យអញជ្រាវលេងទេ

អានាង !"

- នែ៎ ! ពុំយកស្អីមកកប់ទីនេះ មានដឹងថាគល់ស្វាយនេះជាកន្លែងអញទុកស្អីៗទេ ? បានអញចិត្តល្អកាយចេញយកមកក្រៅនោះ ជាសំណាងល្អហើយ ចុះបើអញចិត្តមិនល្អ ហើយជំរុះវត្ថុផ្ទេះផ្ទាបពីលើវិញ វាយ៉ាងម៉េចដែរ ? ម៉េចមិនអរគុណបងស្រីទេឬ ?

ពណ្ណរាយសែនហួសចិត្ត ÷

- ហ្អឹងបងស្រីផង ? នែ៎ ! នាងតូចនាងកើតឆ្នាំអី ? ឆ្នាំនេះគ្នាមានអាយុ ១២ ឆ្នាំហើយណា៎ ! បើអោយគ្នាហៅនាងតូចឯងថាបងស្រីមានវ័យធំជាងគេ មិនមែនស្លៀកខោប៉ោងត្រឹមភ្លៅ ពាក់អាវមានហោ-ប៉ៅធំៗពីរ ដាក់សុទ្ធតែបាយឡកបាយឡអីចឹងទេ !

ដានីសំលឹងអាវនាងមានហោប៉ៅធំៗទាំងសងខាង ទាំងញញឹមខ្ទឹប ។

- ឆ្នាំនេះ ខ្ញុំអាយុ ៦ ឆ្នាំ ! បើគិតពីអាយុវិញ ខ្ញុំប្អូនឯងដល់ទៅ ៦ ឆ្នាំឯណោះ ប៉ុន្តែបើគិតពីរស់នៅក្នុងស្រុកនេះ ខ្ញុំមានអាយុបងឯង ៦ ឆ្នាំដែរ ! ឯងទើបនឹងមកដល់ថ្មីៗ ឯងមិនដឹងទេថា នៅទីនេះគេគោរពអ្នកណា ដែលមានឫកពាជាមនុស្សធំ ! នៅទីនេះ ខ្ញុំត្រូវគេចាត់ទុកជាតំណាងមនុស្សចាស់ ដូច្នេះខ្ញុំត្រូវតែបងឯង !

ពណ្ណរាយពេបមាត់ ÷

- យើងជាមនុស្សធំយើងមានអាយុបងឯង ! ម៉ែឪយើងប្រដៅថា ក្មេងធំឈ្លោះជាមួយក្មេងតូចអន់ណាស់ ដូច្នេះកុំឱ្យអន់ យើងមិន



ឈ្លោះជាមួយឯងទេ ! ឯងត្រូវចេះរៀបឫកពាអោយសមនឹងអាយុផង ឃើញគេបងត្រូវគោរពគេផង !

- យើងមានប្អូនជាច្រើនអាយុលើសឯងផង ឯងដឹងទេឫកពារបស់យើងសមជាមនុស្សធំ ដូច្នេះឯងមិនឈ្លោះជាមួយយើងត្រូវហើយ ព្រោះយើងក៏មិនចូលចិត្តឈ្លោះនឹងក្មេងៗដូចឯងដែរ !

ដានីហៅពណ្ណរាយថាក្មេងៗ ដូចជាវាធំណាស់អញ្ចឹង ពណ្ណរាយរិតតែច្រលោត ÷

- នែ៎ ! មីតូចប៉ុណ្ណឹងទេ ក៏ចង់ធ្វើធំដែរ ! មនុស្សធំឯណាមកជុះអាចម៍នៅគល់ស្វាយដូចមីតូចឯងនោះ ? មិនចេះខ្មាសធម្មជាតិសោះ ! តាំងខ្លួនយ៉ាងនេះទៅរួច !

ដានីមើលមុខពណ្ណរាយយ៉ាងមុត ÷

- នែ៎ ! កុំនិយាយខ្លាំងៗពេក ! បើឯងជាមនុស្សធំម៉េចក៏ស្រែកជំទាលញម្ល៉េះ ? ឯងធ្លាប់ឃើញមនុស្សធំឈ្លោះគ្នាទេ ? មនុស្សធំគេឈ្លោះគ្នាអត់ស្រែកដូចឯងអីចឹងទេ ! គេនិយាយខ្សិបៗ ហើយវ៉ៃគ្នាតែម្តង ! ប្រហែលនៅផ្ទះឯងសំបូរតែមនុស្សមានអាយុច្រើន តែឫកពាជាកូនក្មេងហើយ ទើបកាត់បានមករកឯងស្រែកឡូឡាដូចកូនក្មេងលេងស្វាដណ្តើមទី សមណាស់ស្រែកយ៉ាងនេះដូចជាកូនក្មេង !

- ហ៊ឺស ! នៅតែតាំងខ្លួនជាមនុស្សចាស់ទៀត មើលបើឯងចាស់ឯងអាចមានកូនបានទេ ? ឯងកូនប៉ុន្មានហើយ ?

ដានីចំអកមកវិញថា ÷

- អូហ៎ ! នៅស្រុកឯងចាស់ដោយសារមានកូនឬ ? ចោលម្សៀតណាស់ ! នៅស្រុកយើងនរណាមានកូនច្រើនជាងគេ គេចាត់ទុកជាមនុស្សល្ងង់ ចាស់ល្ងង់ជាមនុស្សអន់ជាងក្មេងជាអ្នកល្ងង់ ព្រោះក្មេងល្ងង់វាអាចកែទៅជាក្មេងឆ្លាតបាន រីឯចាស់ល្ងង់ មានតែងាប់ទេទើបចប់ល្ងង់ ! យើងមិនមែនចាស់ល្ងង់ទេ យើងជាមនុស្សក្មេងអាយុតែចាស់គំនិត ដែលគេនាំគ្នាហៅយើងថា "ក្មេងឆ្លាត១ ហើយប្រៀបទៅនឹងយើងជាមនុស្សឆ្លាតទៀត ដូច្នេះយើងគ្មានកូនទេ ! ព្រោះចាស់ឆ្លាតច្រើនតែអត់កូន ដូចលោកយាយសូត្រគ្រូទាយនៅក្នុងភូមិនេះអីចឹង ! គាត់អត់កូនមួយទេ តែនរណាក៏សរសើរថាគាត់ពូកែដែរព្រោះគាត់ទាយត្រូវណាស់ !

ដានីមិនគួរចេះនិយាយពាក្យទាំងនេះទេ ប៉ុន្តែពាក្យអស់នេះជីតាវាធ្លាប់និយាយប្រាប់គេឯងសួរពីវា ទើបវាចាំបាន ហើយនិយាយកើតដូច្នេះ ។

ពណ្ណរាយរិតតែខឹងហើយផ្ទាន់តទៅទៀតថា ÷

- បើឯងថាឯងធំ តើឯងជិះកប៉ាឯងធ្វើអ្វី ? មនុស្សធំគេមិនដែលអោយប៉ាបីពរទេ !

ដានីពេបមកវិញ ÷

- ចុះឯងអីក៏ភ្លីភ្លើម្ល៉េះ ? បើឯងឈឺជើងដើរមិនរួច ឯងមិនអោយប៉ាឯងពទេឬ ? នៅក្នុងព្រៃកាលណាមានពស់ចឹក គេពមកឱ្យគ្រូខ្មែរមើល ឯងមិនទាន់មកទើបអត់ដឹង ។ យី ! មនុស្សធំនៅស្រុក



ឯងអត់ចេះជួយគ្នាទេឬ ? គេបីពដើម្បីជួយគ្នា វាជារឿងធម្មតារបស់មនុស្សទេតើ !

ពណ្ណរាយរិតតែចង់ឈ្នះទៀត ព្រោះដានីនៅតែឆ្លើយរួចរហូត វាក៏ផ្ទាន់សាជាថ្មី ÷

- បើឯងជាមនុស្សធំ ម៉េចក៏ឯងចងសក់កំប៉ោយពីរ ? ឯងមើលមនុស្សធំមាននរណាចងសក់ដូចឯង ?

ដានីគ្រវីសក់ហើយឆ្លើយដោយស្រួល ÷

- គេជាមនុស្សធំទាំងអាយុ ធំទាំងគំនិត គេចាំបាច់ចងធ្វើអ្វី រីឯយើងក្មេងអាយុ តែចាស់ទុំខាងគំនិត ត្រូវចងឱ្យខុសគេស្រួលចំណាំ ! ឯងនេះអត់ដឹងអីសោះ ! នៅភូមិនេះគេអាចស្គាល់យើងបាន ដោយសារសក់ចងកំប៉ោយនេះណា៎ !

- វាមិនខ្មោចទេ យើងមិនព្រមជឿថាឯងជាក្មេងធំឡើយយើងនៅតែហៅឯងថាមីតូច១ ឯងធ្វើអីយើង ?

ដានីឆ្លើយបែបហ៊ី ÷

- ចុះយើងបានប្រាប់ឯងហើយថា យើងជាក្មេងចាស់គំនិតយើងមិនឈ្លោះនឹងក្មេងទេ ឯងហៅយើងថាមីតូច១ដូចជាសមដែរ ព្រោះមីតូច១ បញ្ជាក់ថាយើងនៅក្មេង ឯងថែមពាក្យខាងចុងបន្តិចថា "មីតូចដ៏ឆ្លាត" នោះគ្រប់គ្រាន់ហើយ !

ពណ្ណរាយស្រែកវ៉ាស ÷

- មីតូចកំភ្លើ ! មីតូចដ៏ឆ្កួត ! មីតូចឡប់១ !